01241528

E405/1

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-May-2016, 12:10
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើង**
**ដោយភាគីដាក់ឯកសារ:** **សាធារណៈ:**
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ:/Public
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើរបស់ នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹង ALEXANDER HINTON (2-TCE-88)**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តី:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

# I. សេចក្តីផ្តើម

១. សំណើរបស់ នួន ជា ដែលស្នើឲ្យបង្គាប់ទៅសាក្សីជំនាញ Alexander Hinton (2-TCE-88) ផ្តល់នូវប្រភពចំបងនៃសម្ភារៈស្រាវជ្រាវ ទាក់ទងនឹងការរៀបចំសៀវភៅរបស់គាត់នោះ[1] ("សំណើ") គួរត្រូវបានបដិសេធចោល[2] ដោយសារតែសំណើនេះ (i) មិនចំពេលវេលា; (ii) មានតម្លៃស្មើនឹង "ការវាវម្ហូលក្នុងសមុទ្រ"; (iii) ជាការប៉ុនប៉ងយឺតពេលដើម្បីតវ៉ាទៅនឹងជំនាញរបស់ Hinton និង (iv) ជាលទ្ធផលអាចបង្កឲ្យមានការពន្យារពេលមិនត្រឹមត្រូវ ដល់ដំណើរការនីតិវិធី។ ប៉ុន្តែ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ជឿថា វានឹងនាំឲ្យដល់ការបញ្ជាក់អំពីការពិត នោះសហព្រះរាជអាជ្ញាស្នើឲ្យកោះហៅសាក្សី 2-TCW-884 ដែល នួន ជា បានសន្មតថាជាប្រភពមួយដែល Hinton បានពឹងផ្អែកនោះ មកបំភ្លឺផងដែរ។

# II. សេចក្តីសន្និដ្ឋាន

## *(i) សំណើធ្វើឡើងយឺតពេល*

២. នួន ជា បានដឹងអំពីភ័ស្តុតាងដែលបានស្នើឡើងរបស់ Hinton យ៉ាងហោចណាស់ក៏តាំងពីខែឧសភា ឆ្នាំ២០១៤ ដែរ គឺនៅពេលដែល កសព និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើឲ្យកោះហៅ Hinton ធ្វើជាអ្នកជំនាញ[3]។ តាមពិត នួន ជា បានស្នើសុំឲ្យ Hinton មកបំភ្លឺនៅ

[1] **E3/3346** Alexander Hinton, ("ហេតុអ្វីបានជាគេសម្លាប់"?) 'Why Did They Kill?'

[2] **E405** សំណើរបស់ នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (សំណើសុំឯកសារ) ទាក់ទិននឹង Alexander Laban Hinton (2-TCE-88), ៩ ឧសភា ២០១៦។

[3] <u>កសព</u>: **E301/2/1.1** ឧបសម្ព័ន្ធ ក: ផែនការសវនាការ និងសេចក្តីព្រាងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា សម្រាប់សំណុំរឿង០០២/០២, ១១ ធ្នូ ២០១៣, EN 00965524។ **E307/3/2.2** ឧបសម្ព័ន្ធ I: បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញា ដែលបានកែសម្រួលបញ្ចូលគ្នាសម្រាប់សំណុំរឿង០០២/០២ តាមលំដាប់នៃវគ្គសវនាការតាមការផ្តល់អនុសាសន៍ និងការបង្ហាញខ្លួន, ២៨ កក្កដា ២០១៤, EN 01003004។ **E305/6.1** ឧបសម្ព័ន្ធ I: បញ្ជីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរួមបញ្ចូលគ្នារបស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង០០២/០២ តាមលំដាប់នៃវគ្គសវនាការតាមការផ្តល់អនុសាសន៍ និងការបង្ហាញខ្លួន, ៩ ឧសភា ២០១៤, EN 00986545។ **E305/6.2** ឧបសម្ព័ន្ធ II: បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ កសព ដែលបានធ្វើបច្ចុប្បន្នភាព, ៩ ឧសភា ២០១៤, EN 00986563។ **E305/7.1.3** ឧបសម្ព័ន្ធ III: សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានធ្វើបច្ចុប្បន្នភាព, ១៦ ឧសភា ២០១៤, EN 00986497។ **E305/6.4** ឧបសម្ព័ន្ធ III: សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ សពអ ដែលបានធ្វើបច្ចុប្បន្នភាព, ៩ ឧសភា ២០១៤, EN 00986617។ <u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:</u> **E305/7.1.1** ឧបសម្ព័ន្ធ I – បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានធ្វើ

ក្នុងសំណុំរឿង០០២/០១ បើទោះបីជាគាត់ជាចុងក្រោយមិនត្រូវបានកោះហៅក្តី[4]។ សៀវភៅរបស់ Hinton ដែលមានចំណងជើងថា "Why Did They Kill"("ហេតុអ្វីបានជាគេសម្លាប់"?) ដែលគាត់រៀបរាប់ពីវិធីសាស្ត្រ និងការប្រើប្រាស់សម្ភារៈជាប្រភពរបស់គាត់[5] ត្រូវបានដាក់ទៅក្នុងសំណុំរឿង០០២ តាំងពីឆ្នាំ២០១២[6]។

៣. ភាគីត្រូវបានជូនដំណឹងដោយអង្គជំនុំជម្រះ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ថា Hinton នឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃទី១៤-១៧ ខែមីនា ឆ្នាំ២០១៦[7]។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៦ នួន ជា បានស្នើឱ្យទទួលយកជាភ័ស្តុតាងនូវឯកសារ "ដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈនៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងសៀវភៅរបស់ Hinton ដែលមានចំណងជើងថា "Why Did They Kill" នេះផង ដែលនឹង "ផ្តល់តម្លៃភរនីយភាពចំពោះសៀវភៅរបស់គាត់ផង និងជាភ័ស្តុតាងឱ្យគាត់ផ្តល់ក្នុងសវនាការផង"[8]។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦ គឺប៉ុន្មានសប្តាហ៍បន្ទាប់ពី Hinton បានផ្តល់សក្ខីកម្មរួច នួន ជា បានស្នើឱ្យទទួលយកសម្ភារៈមួយចំនួនបន្ថែមទៀតជាភ័ស្តុតាង ដើម្បីតវ៉ាចំពោះភ័ស្តុតាងរបស់ Hinton[9]។

---

បច្ចុប្បន្នភាព, ១ កក្កដា ២០១៤, EN 00986456។ **E305/7.1.3** ឧបសម្ព័ន្ធ III: សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានធ្វើបច្ចុប្បន្នភាព, ១៦ ឧសភា ២០១៤, EN 00986497។

[4] **E93/4.3** សម្ភារៈកំពុងត្រៀមរៀបចំសម្រាប់ដំណើរការនីតិវិធីសវនាការ: សេចក្តីសង្ខេបសាក្សី - ក្រុមមេធាវីការពារក្តី នួន ជា, ២១ មិថុនា ២០១១, EN 00708009។ **E312.2** ឧបសម្ព័ន្ធ II- បុគ្គលដែលត្រូវបានភាគីស្នើឡើង ទាក់ទងនឹងសំណុំរឿង០០២/០១ ប៉ុន្តែ មិនទាន់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅឡើយ, ៧ សីហា ២០១៤, EN 01004778។

[5] *សូមមើល ជាឧទាហរណ៍* **E3/3346** Alexander Hinton, ("ហេតុអ្វីបានជាគេសម្លាប់"?) 'Why Did They Kill?', EN 00431458; EN 00431435-00431436; EN 00431463-00431473; EN 00431743-00431791។

[6] **E185/1.3,** ឧបសម្ព័ន្ធ គ - សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញានិងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត, ៣ ធ្នូ ២០១២, EN 00884569។

[7] **E405.1.1** សារអេឡិចត្រូនិក ពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ជូនគូភាគី, ១២ កុម្ភៈ ឆ្នាំ២០១៦។

[8] **E387** សំណើលើវិធាន ៨៧(៤) របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារចំនួន១៧ ទាក់ទងនឹងសក្ខីកម្មរបស់ Alexander Laban Hinton (2-TCE-88), ៣ មីនា ២០១៦, កថាខណ្ឌ៣៤។

[9] **E396** សំណើរបស់ នួន ជា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកចុតហ្សាយចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ, ៨ មេសា ២០១៦។ *សូមមើល* ផងដែរ **E396/3** សារណាតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤)

៤. ដូច្នេះ នួន ជា បានដឹងអំពីសៀវភៅរបស់ Hinton តាំងពីយូរណាស់មកហើយ ដោយផ្អែកលើសម្ភារៈប្រភពដើម ហើយមានឱកាសច្រើនសន្ធឹកសន្ធាប់ដើម្បីស្នើសុំសម្ភារៈដូច្នេះ។ ជម្រើសរបស់គាត់មិនព្រមធ្វើដូច្នេះរហូតដល់រយៈពេលប្រាំពីរសប្តាហ៍ក្រោយសក្ខីកម្មរបស់ Hinton - និងបន្ទាប់ពីមានសំណើសុំភ័ស្តុតាងបន្ថែមចំនួនពីរ ដែលសួរផ្ទាល់ចំៗចំពោះសក្ខីកម្មរបស់ Hinton នោះ - បង្ហាញឲ្យឃើញពីកង្វះការយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ ឬជាការប៉ុនប៉ងមួយដើម្បីពន្យារចំពោះកិច្ចដំណើរការនីតិវិធី។

៥. តាមការឲ្យដឹងរបស់ នួន ជា ដែលថាសំណើមិនត្រូវបានធ្វើឡើងតាំងពីដំបូងដោយសារគាត់ "កំពុងតែសង្ឃឹមដើម្បីទាញយកព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់ប្រភពនានារបស់ Hinton នៅក្នុងអំឡុងនៃការសួរដេញដោលគាត់នៅក្នុងសាលសវនាការនោះ" គឺមិនសមហេតុផលទេ[10]។ ការណ៍ដែលគ្រាន់តែសង្ឃឹម ដើម្បីទទួលបានប្រភេទព័ត៌មានជាក់លាក់ណាមួយពីសក្ខីកម្មរបស់ Hinton មិនបានរារាំង នួន ជា ពីការស្នើសុំព័ត៌មានដូច្នេះពីដំបូងឡើយ ហើយម៉្លេះក៏បានប្រាប់ Hinton ឲ្យបានដឹងនិងយកសម្ភារៈនោះមកតាមខ្លួនគាត់ទៅហើយ ប្រសិនបើអាច។ តាមពិត ដូច Hinton បានផ្តល់សក្ខីកម្មដូច្នេះថា "ប្រសិនបើខ្ញុំបានដឹងមុនពេលខ្ញុំមកទីនេះថាមានគេស្នើសុំព័ត៌មាននេះម៉្លេះខ្ញុំបានធ្វើវា និងបានពិនិត្យកំណត់ហេតុរបស់ខ្ញុំជាប្រព័ន្ធរួចជាស្រេចហើយ"[11]។

*(ii) សំណើទូលំទូលាយពេក*

៦. ជំនួសឲ្យការស្វែងរកអត្តសញ្ញាណនៃប្រភពរបស់ Hinton - ដូច នួន ជា អះអាងពីចេតនារបស់គាត់ក្នុងអំឡុងនៃការផ្តល់សក្ខីកម្មរបស់ Hinton[12] - ឥឡូវនេះ នួន ជា កំពុងតែស្នើសុំប្រភពចំបងនៃសម្ភារៈស្រាវជ្រាវទាំងអស់ដែល Hinton បានចងក្រងសម្រាប់សៀវភៅរបស់គាត់ រួមមាន ការស្ទាបស្ទង់មតិប្រជាជន៩៥-១០០នាក់ ខ្សែអាត់សម្លេង ប្រតិចារឹក សំណៅបកប្រែ និងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរទាំងអស់នៃបទសម្ភាន៍ ហើយនឹងក្រដាសលេខកូដសម្ងាត់នៃរហស្សនាមជាប្រភព[13]។ ដូច្នេះសំណើនេះ ទូលំទូលាយពេកមានតម្លៃស្មើនឹងការវាវម្ជុលក្នុងសមុទ្រ[14]។

---

នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកជាភ័ស្តុតាង ទាក់ទិននឹងសម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា នរោត្តម សីហនុ, ៣ ឧសភា ២០១៦។

[10] **E405** សំណើ, កថាខណ្ឌ២៧។

[11] **E1/403.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មីនា ២០១៦, EN 01219446, បន្ទាត់ទី 1-4។

[12] **E405** សំណើ, កថាខណ្ឌ២៧។

[13] **E405** សំណើ, កថាខណ្ឌ៤០(ក)។

៧. ដោយស្នើឱ្យអង្គជំនុំជម្រះទទួលយកសម្ភារៈនេះ នួន ជា ពឹងផ្អែកលើយុត្តិសាស្ត្រដែលមិនអាចអនុវត្តបាននៅក្នុងកាលៈទេសៈបច្ចុប្បន្ន[15]។ របាយការណ៍នានារបស់អ្នកជំនាញនៅឯសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានរៀបចំឡើងដោយមានការឯកភាពគ្នាចំពោះព្រំដែនកំណត់របស់ភាគីដែលស្នើសុំ ឬអង្គជំនុំជម្រះ សម្រាប់ករណីជាក់លាក់ណាមួយ។ ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ដោយឯករាជ្យរបស់ Hinton សម្រាប់គោលបំណងនៃអំណះអំណាងសម្រាប់សញ្ញាបត្របណ្ឌិត និងសៀវភៅបន្ទាប់ - មួយចំណែកគឺជាមូលដ្ឋាននៃការចាត់តាំងរបស់គាត់ក្នុងនាមជាអ្នកជំនាញក្នុងការសិក្សា អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយអង្គជំនុំជម្រះ[16] - មិនមានសទិសភាពទេ។ ជាការបន្ថែម ខណៈពឹងផ្អែកទៅលើយុត្តិសាស្ត្ររបស់សាលាក្តី*ចំពោះកិច្ច* នានា នួន ជា ខកខានមិនបានធ្វើកត់សំគាល់ថា តុលាការ ICTY តម្រូវឱ្យគូភាគីដាក់ការតវ៉ាណាមួយទៅនឹងគុណវុឌ្ឍិ ឬរបាយការណ៍/កំណត់ហេតុរបស់អ្នកជំនាញណាម្នាក់"ក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃនៃការដាក់បង្ហាញកំណត់ហេតុ/ឬរបាយការណ៍របស់សាក្សីជំនាញរូបនោះ"[17]។

៨. សន្និទានភាពនៃសំណើសុំ មានន័យថា គ្រប់អ្នកជំនាញទាំងអស់ដែលបានកោះហៅមកចំពោះមុខអង្គជំនុំជម្រះ អាចនឹងតម្រូវឱ្យផ្តល់គ្រប់ចំណុចនៃប្រភពចំបងនៃសម្ភារៈស្រាវជ្រាវទាំងអស់ដែលគាំទ្រចំពោះមតិយោបល់ជំនាញរបស់ពួកគាត់។ ការណ៍នេះច្បាស់ណាស់ថានឹងធ្វើឱ្យខូចដល់គោលបំណងនៃការកោះហៅអ្នកជំនាញផង និងធ្វើឱ្យមានការពន្យារពេលហួសហេតុដល់កិច្ចដំណើរការនីតិវិធីផង។ លើសពីនេះ គោលជំហរមិនច្បាស់លាស់របស់ នួន ជា ដែលថាមតិយោបល់របស់អ្នកជំនាញម្នាក់ដែលផ្អែកលើប្រភពគ្មានឈ្មោះមិនអាចពឹងផ្អែកបាននោះ គឺវាផ្ទុយគ្នាទៅនឹងការខកខានរបស់គាត់ដែលមិនបានស្នើសុំប្រភពពីអ្នកជំនាញដែលខ្លួនគាត់ផ្ទាល់បានស្នើសុំដែរ។ Michael Vickery ត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មក្នុងវគ្គសវនាការខាងមុខ ស្តីពីការបោសសម្អាត។ សំណេររបស់គាត់ស្តីពីកម្ពុជា បានពឹងផ្អែកច្រើនក្រៃលែងដែរលើប្រភពដែលគាត់សំដៅទៅរក

---

[14] *សូមមើល* **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កថាខណ្ឌ២៣។

[15] **E405** សំណើ, កថាខណ្ឌ២០-២១។

[16] **E388** សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88, កថាខណ្ឌ១៣-១៤។

[17] សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, វិធានស្តីពីនីតិវិធី និងភស្តុតាង, IT/32/។វិសោធនកម្មលើកទី៤៩, ២២ ឧសភា ២០១៣, វិធាន៩៤ស្ទួន(ខ)។

ដោយប្រើតែអាទិសង្កេត នៅក្នុងសៀវភៅរបស់គាត់ប៉ុណ្ណោះ ដើម្បីរក្សាការសម្ងាត់[18]។ រហូតមកដល់ពេលនេះ នួន ជា មិនបានស្នើសុំឱ្យអង្គជំនុំជម្រះបង្ខំ Vickery បង្ហាញឈ្មោះនៃប្រភពរបស់គាត់ទេ[19]។

*(iii) សំណើនេះគឺជាការប៉ុនប៉ងដ៏យឺតយូរដើម្បីជំទាស់ទៅនឹងជំនាញរបស់លោក Hinton*

៩. នួន ជា ធ្លាប់ត្រូវបានផ្តល់ឱកាសឱ្យជំទាស់ទៅនឹងការចាត់តាំងរបស់លោក Hinton ជាអ្នកជំនាញ ហើយបានជ្រើសរើសមិនធ្វើដូច្នោះទេ។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានអញ្ជើញភាគីនានាឱ្យធ្វើការសង្កេតទៅលើការលើកឡើងចោទប្រកាន់របស់ ខៀវ សំផន[20] ដែលថា នៅក្នុងចំណោមនោះ លោក Hinton មិនមានឯករាជទេ ដោយមកពីគាត់ការងាររបស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា[21]។ នួន ជា មិនបានធ្វើការដាក់ជូនណាមួយនោះទេ[22]។

១០. លើសពីនេះ សំណើនេះបានកម្រិតដោយខុសឆ្គងទៅលើជំនាញរបស់លោក Hinton ក្នុងការស្រាវជ្រាវដែលគាត់បានដំណើរការនៅក្នុងប្រទេសកម្ពុជា នៅដើមទសវត្សរ៍ ១៩៩០[23]។ ដូចដែលវាបានច្បាស់ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដោយបានចាត់តាំងលោក Hinton ជាអ្នកជំនាញម្នាក់ ដែលជំនាញរបស់គាត់នៅក្នុងការសិក្សាអំពីអំពើប្រល័យពូជសាសន៍គឺទូលំទូលាយជាងកិច្ចការរបស់គាត់នៅក្នុងប្រទេសកម្ពុជា - ដែលបានបង្កើតជាផ្នែកនៃមូលដ្ឋាននៃសៀវភៅនេះ - ហើយបានដាក់បញ្ចូលនូវចំណេះដឹងជំនាញ និងបទពិសោធន៍ដែលទទួលបានមកពីឋានៈបណ្ឌិត

[18] **E3/1757** Michael Vickery 'កម្ពុជា ១៩៧៥-១៩៨២'។

[19] *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង Charles Taylor*, SCSL-03-1-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំដាក់បង្ហាញអត្តសញ្ញាណរបស់ "ប្រភព" សម្ងាត់ដែលបានលើកឡើងក្នុងអំឡុងពេលសួរដេញដោលសាក្សី ភាគីបដិបក្សនៃ TF1-355, ៦ មីនា ២០០៩។

[20] **E1/240.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៣០ កក្កដា ២០១៤, ទំព័រ ៥៩, ៦៣-៦៥។

[21] **E305/9** សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះការកោះហៅបុគ្គលមួយចំនួនដែលស្នើមកផ្តល់សក្ខីកម្មសម្រាប់សំណុំរឿង ០០២/០២ និងសំណើសុំការបំភ្លឺលើវិសាលភាពជាក់លាក់នៃការពិភាក្សាដេញដោលបន្ទាប់ពីសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង E301/9/1, ៣០ ឧសភា ២០១៤, កថាខណ្ឌ៣៩-៤០។

[22] **E388** សេចក្តីសម្រេចតែងតាំងអ្នកជំនាញ 2-TCE-88, កថាខណ្ឌ៨។

[23] **E405** សំណើ កថាខណ្ឌ ៥-៨។

សភា និង ការស្រាវជ្រាវរបស់គាត់[24]។ បន្ថែមលើនេះ វាជាការជាក់ស្តែងដែលថាសៀវភៅរបស់លោក Hinton បានតាក់តែងឡើងនៅលើប្រភពនានាដែលហួសពីការស្រាវជ្រាវដែលគាត់បានដំណើរការនៅក្នុងប្រទេសកម្ពុជា ហើយថាសក្ខីកម្មជំនាញរបស់គាត់មានមូលដ្ឋាននៅលើការស្រាវជ្រាវដែលបានដំណើរការស្រាវជ្រាវដែលបានដំណើរការបន្ទាប់ពីសៀវភៅរបស់គាត់ត្រូវបានបោះពុម្ពផ្សាយ ក៏ដូចជាប្រភពផ្សេងៗទៀតដែរ[25]។ ការអះអាងរបស់ នួន ជា ដែលថា "ពុំមានភ័ស្តុតាងដែលថា លោក Hinton ពិតជាបានធ្វើការស្រាវជ្រាវដល់ទីកន្លែងនៅប្រទេសកម្ពុជា" គឺពុំគួរឱ្យជឿជាក់បាននោះទេ[26]។

១១. ការអះអាងរបស់ នួន ជា ដែលថា គាត់ "ពិតជាត្រូវបានរារាំងមិនឱ្យជំទាស់ទៅនឹងមូលដ្ឋានដែលអាចមាន ដែលលោក Hinton យកមកសំអាងក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន" គឺពុំមានអង្គសេចក្តីទេ[27]។ ការសួរដេញដោលរបស់គាត់លើលោក Hinton បានផ្តល់នូវឱកាសនោះ។ នួន ជា បានធ្វើការពិនិត្យយ៉ាងទូលំទូលាយលើលោក Hinton ដោយទាក់ទងទៅនឹងកិច្ចការ របស់គាត់ និងបានប្រើប្រាស់សម្ភារៈផ្សេងពីការស្រាវជ្រាវរបស់គាត់នៅប្រទេសកម្ពុជា ហើយ លោក Hinton បានឆ្លើយយ៉ាងច្បាស់នូវសំណួរបែបដូច្នោះ[28]។ នួន ជា មិនបានកំណត់អត្តសញ្ញាណថា

---

[24] **E388** សេចក្តីសម្រេចតែងតាំងអ្នកជំនាញ 2-TCE-88, កថាខណ្ឌ ១៣-១៤។

[25] *សូមមើល ជាឧទាហរណ៍* **E1/401.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៤ មីនា ២០១៦, EN 01217257, បន្ទាត់ 5-14។ EN 01217276, បន្ទាត់20- EN 01217278, បន្ទាត់23។ **E1/402.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១៦, EN 01218202, បន្ទាត់8-14។ EN 01218207, បន្ទាត់8-21។ EN 01218208, បន្ទាត់15-23។ EN 01218209, បន្ទាត់7-11។ EN 01218298, បន្ទាត់1-5។ EN 01218307, បន្ទាត់15- EN 01218311, បន្ទាត់1។ EN 01218324, បន្ទាត់1- EN 01218324, បន្ទាត់9។ EN 01218327, បន្ទាត់25- EN 01218328, បន្ទាត់25។ **E1/403.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មីនា ២០១៦, EN 01219439, បន្ទាត់15- EN 01219440, បន្ទាត់8។ EN 01219455, បន្ទាត់6-24; EN 01219561, បន្ទាត់13-19។ **E1/404.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៧ មីនា ២០១៦, EN 01221404, បន្ទាត់8-17។

[26] **E405** សំណើ កថាខណ្ឌ៣៤។

[27] *ដដែលដូចខាងដើម*, កថាខណ្ឌ៣៦។

[28] *សូមមើល ជាឧទាហរណ៍* **E1/402.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១៦, EN 01218298, បន្ទាត់1-5។ EN 01218307, បន្ទាត់15- EN 01218311, បន្ទាត់1។ EN 01218308, បន្ទាត់8-22។ EN 01218309, បន្ទាត់8- EN 01218311, បន្ទាត់23។ EN 01218315, បន្ទាត់16- EN 01218316, បន្ទាត់18។ EN 01218318, បន្ទាត់12-17។ EN 01218321, បន្ទាត់2- EN 01218322, បន្ទាត់5។ EN 01218324, បន្ទាត់1- EN 01218324, បន្ទាត់9។ EN 01218327, បន្ទាត់25- EN 01218328, បន្ទាត់25។ **E1/403.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មីនា ២០១៦, EN 01219437, បន្ទាត់24- EN 01219440, បន្ទាត់8។ EN 01219440, បន្ទាត់21- EN 01219442, បន្ទាត់7។ EN 01219443, បន្ទាត់9-16។

តើអង្គហេតុណាខ្លះដែលនៅពេលនេះ គាត់មានបំណងជំទាស់ ឬ ពន្យល់ថាតើ ហេតុអ្វីបានគាត់មិនអាចជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់លោក Hinton ដោយមានមូលដ្ឋាននៅលើភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង នៅពេលដែលគាត់មានឱកាស។

*(iv) សំណើនេះ បើសិនជាទទួលយក នឹងត្រូវពន្យារកិច្ចដំណើរការនីតិវិធីដោយមិនចាំបាច់*

១២. លោក Hinton បានបញ្ជាក់ថា នៅពេលដែលធ្វើសក្ខីកម្មថាគាត់នឹងត្រូវពិគ្រោះជាមួយនឹងសាកលវិទ្យាល័យរបស់គាត់ទាក់ទងនឹងពិធីសារស្តីពីប្រភព ក៏ដូចជាទាក់ទងប្រភពបុគ្គលនានាដើម្បីសួរថាតើគាត់អាចប្រើឈ្មោះរបស់ពួកគាត់ នៅមុនពេលចេញប្រភពសម្ភារៈដែរឬទេ[29]។ ដោយហេតុថាលោក Hinton បានជួបនិយាយជាមួយមនុស្សប្រហែលជា ២០០នាក់ សម្រាប់ជាគោលបំណងនៃកិច្ចការរបស់គាត់នៅក្នុងប្រទេសកម្ពុជា[30] គេច្បាស់ណាស់ថា ការណ៍នេះនឹងជានីតិវិធីមួយដែលស៊ីពេលវេលា។ បន្ថែមលើនេះ វាទំនងជាមានការលេចឡើងពីក្នុងសក្ខីកម្មរបស់គាត់ដែលថា លោក Hinton បានដំណើរការបទសម្ភាសន៍របស់គាត់ជាភាសាខ្មែរ ហើយវាមិនច្បាស់ទេថា តើមានការបកប្រែភាសាដែរឬក៏អត់[31]។ នីតិវិធីនៃការបកប្រែនៃកំណត់ត្រាបែបដូច្នោះ បើចាំបាច់ ទំនងជានឹងត្រូវចំណាយពេលរាប់ខែ។

១៣. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបញ្ជាក់ពីក្តីបារម្ភ - ដោយយោងទៅលើអាយុរបស់ជនត្រូវចោទ និងអ្នកដែលមិនប្រាកដផ្សេងៗទៀត[32] - ថាសំណើសុំឱ្យមានកិច្ចស៊ើបសួរយ៉ាងទូលំទូលាយដែលស្រដៀងគ្នា ដោយ នួន ជា នឹងមិនត្រូវបានបំពេញទេនៅក្នុងរយៈពេលដ៏សមហេតុសមផលមួយ ដោយមានមូលដ្ឋាននៅលើចំនួនពេលវេលាដែលវាត្រូវស៊ីនៅលើភាគីនានាដែលត្រូវពិនិត្យសារឡើង

EN 01219446, បន្ទាត់1- EN 01219447, បន្ទាត់13។ EN 01219448, បន្ទាត់14- EN 01219449, បន្ទាត់7។ EN 01219450, បន្ទាត់16- EN 01219452, បន្ទាត់11។

[29] **E1/402.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១៦, EN 01218217, បន្ទាត់19-25។ **E1/403.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មីនា ២០១៦, EN 01219435, បន្ទាត់17-19។

[30] **E1/403.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មីនា ២០១៦, EN 01219438, បន្ទាត់12-14។ EN 01219446, បន្ទាត់5-16។

[31] **E1/401.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៤ មីនា ២០១៦, EN 01217259, បន្ទាត់2-8។

[32] **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភស្តុតាងថ្មី, ឲ្យចាប់ផ្តើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កថាខណ្ឌ២៤។

វិញនូវព័ត៌មាន និងសម្រាប់ការបកប្រែវា[33]។ ដែលថា នួន ជា ក៏កំពុងស្វែងរកឱកាសផងដែរដើម្បី "ធ្វើសេចក្ដីសន្និដ្ឋានថាតើ គួរទទួលយកប្រភពព័ត៌មានទាំងនោះធ្វើជាភស្តុតាង ឬយ៉ាងណា" និង "ថាតើត្រូវមានវិធានការអ្វីបន្ថែមទៀត"[34] បកស្រាយបន្ថែមទៀតអំពីរបៀបដែលសំណើ - ដែលខកខានមិនបានបង្ហាញអំពីរបៀបដែលភាព ត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីគឺ ឬ អាចត្រូវបានប៉ះពាល់ - នឹងរារាំងដល់កាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការធានាឲ្យបាននូវការកាត់សេចក្ដីមួយដ៏ឆាប់រហ័ស[35]។

### *(v) វិធានការផ្សេងទៀត គឺនៅអាចរកបាន*

១៤. ក្នុងអំឡុងពេលសក្ខីកម្មរបស់លោក Hinton នួន ជា បានលើកឡើងពីអត្តសញ្ញាណនៃប្រភពជាក់លាក់ដែលបានយោងទៅរកដោយលោក Hinton[36]។ ទោះបីជាលោក Hinton មិនអាចបញ្ជាក់បានពីអត្តសញ្ញាណនៃប្រភពរបស់គាត់ដែលបានស្គាល់ដោយរហស្សនាម "ទាប"[37] ក៏ នួន ជា បានថ្លែងថាគាត់គឺ "បញ្ជាក់ឲ្យបានច្បាស់" ថាគឺជាសាក្សី 2-TCW-884[38]។ សំណើនេះក៏បានលើកឡើងផងដែរពីកង្វល់របស់ នួន ជា អំពីអត្តសញ្ញាណរបស់ "ទាប"[39] ក៏ប៉ុន្តែមិនបានពន្យល់ថាតើហេតុអ្វីបានជាវិធានការមួយ ដូចជា សួរថាតើសាក្សី 2-TCW-884 ដែលត្រូវបានហៅឲ្យមកផ្ដល់សក្ខីកម្ម មិនត្រូវបានឆ្លើយតបទៅនឹងការអះអាងរបស់គាត់ថា "ពុំមានភស្តុតាងដែលលោក Hinton [...] មិនបានផ្ដល់ការយោងជាក់លាក់ទៅបុគ្គល"[40]។ កសព សូមជូនជា

---

[33] *ដដែលដូចខាងដើម*។

[34] **E405** សំណើ កថាខណ្ឌ៤០(ខ)-(គ)។

[35] **E294/1** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភស្តុតាងថ្មី, ឲ្យចាប់ផ្ដើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣, កថាខណ្ឌ១៩ ដោយបានលើកឡើង នៅក្នុងចំណោមនោះ មានមាត្រា ៣៣*ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានរួមបញ្ចូលនូវវិសោធនកម្មនានា ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

[36] **E1/402.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១៦, EN 01218211, បន្ទាត់ ៤-១៨។

[37] *ដដែលដូចខាងដើម*, EN 01218215, បន្ទាត់ ២១-២៥– EN 01218216, បន្ទាត់ ២-២១។

[38] **E1/402.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១៦, EN 01218214, បន្ទាត់ ១៩-២០។ **E1/403.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៦ មីនា ២០១៦, EN 01219434បន្ទាត់ ៤-៩។

[39] **E405** សំណើ កថាខណ្ឌ៨, ១២។

[40] *ដដែលដូចខាងដើម*, កថាខណ្ឌ៣៤។

សេចក្តីសន្និដ្ឋានថា ការកោះហៅសាក្សី 2-TCW-884 ឱ្យមកផ្តល់សក្ខីកម្ម គឺជាវិធាន ការមួយផ្សេងទៀតដ៏ត្រឹមត្រូវ។ បើសាក្សី 2-TCW-884 មិនមែនជា "ទាប" ដែលលោក Hinton បាននិយាយនោះ វានៅតែទំនងជាកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់ ដែលគាត់អាចផ្តល់ជូននូវព័ត៌មានសំខាន់អំពីឧក្រិដ្ឋកម្មនានា, ជាពិសេសអំពីការចាប់ខ្លួន និងសម្លាប់ ប្រជាជនចាម, អតីតទាហាន លន់ នល់ និង ពួកកម្មាភិបាល បកក, នៅក្នុងតំបន់៤១ ដែលជាប្រធានបទនៃការសួរដេញដោលរបស់ នួន ជា លើលោក Hinton[41]។

## III. ដំណោះស្រាយដែលស្នើឡើង

ចំពោះមូលហេតុដែលបានថែងនៅខាងលើនេះ សំណើនេះគួរត្រូវបានបដិសេធចោលទាំងស្រុង។ ជាជម្រើសផ្សេងទៀត កសព ស្នើថាសាក្សី 2-TCW-884 ត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្ម៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[41] *សូមអាន* ជាឧទាហរណ៍ **E1/402.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ១៥ មីនា ២០១៦, EN 01218297, បន្ទាត់17-19។ EN 01218315, បន្ទាត់16-18។ កសព ធ្លាប់បានស្នើឱ្យកោះហៅសាក្សី 2-TCW-884, សូមអាន **E305/6.1** ឧបសម្ព័ន្ធ I: បញ្ជីរួមរបស់សហព្រះរាជអាជ្ញាស្តីពី សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ សម្រាប់សំណុំរឿង០០២/០២ តាមលំដាប់លំដោយនៃផ្នែកសវនាការ និង ការបង្ហាញខ្លួន, ៩ ឧសភា ២០១៤, EN 00986546។